# បរាភវសូត្រ - ភពនៃសេចក្ដីវិនាស
# មាន ១២ យ៉ាង ៖

(ដកស្រង់ចេញពីឯកសារ គិហិប្រតិបត្តិពិស្ដារ – រៀបរៀងដោយ ភិក្ខុ វិសុទ្ធិញ្ញាណ រស់-កែវ
បោះពុម្ពដោយ បណ្ណាគារ គីម សេង ភព ឆ្នាំ១៩៦៦)

1- *អ្នកដែលចំរើន តថាគតស្គាល់ងាយ* *អ្នកដែលអន្តរាយ តថាគតស្គាល់ពិត*
*អ្នកប្រាថ្នាធម៌ល្អិតល្អក្នុងចិត្ត* *ហើយខំប្រព្រឹត្ត នឹងបានចម្រើន ។*

2- *អ្នកដែលស្រឡាញ់ ពេញចិត្តស្នេហា* *តែនឹងមនុស្សណា អសប្បុរស*
*តែងមិនស្រឡាញ់ ពេញចិត្តទាំងអស់* *នឹងអ្នកសប្បុរស មកធ្វើជាមិត្ត*
*សេចក្ដីស្រឡាញ់ ពេញចិត្តគំនិត* *ហើយទៅគប់មិត្តអសប្បុរស*
*គាប់ចិត្តក្នុងធម៌ ឬមួយរបស់* *ហេតុនោះទាំងអស់ នាំឲ្យវិនាស ។*

3- *អ្នកដេកច្រើនមួយ និយាយច្រើនមួយ* *និងអ្នកឥតព្រួយឥតគិតប្រឹងប្រែង*
*អ្នកខ្ជិលប្រអូស មិនមានខ្នះខ្នែង* *ខឹងច្រើនសំដែង ឲ្យគេឃើញបាន*
*ហេតុធម៌ទាំងនោះ មិនជាកល្យាណ* *នាំឲ្យខកខាន ខាតខូចប្រយោជន៍*
*មានជាប្រធាន តិចច្រើនដោយហោច* *នាំបង់ប្រយោជន៍ ហើយឲ្យវិនាស ។*

4- *នរជនណា មានទ្រព្យធនធាន* *ហើយខ្លួនមិនបាន ចិញ្ចឹមរក្សា*
*មាតាបិតា ដែលចាស់ជរា* *ហេតុនោះទៅជា នាំឲ្យវិនាស ។*

5- *ជនបញ្ឆោតព្រាហ្មណ៍ ឬពួកសមណៈ* *ពួកស្មូមឬអ្នក ដទៃៗ*
*ដោយមុសាវាទ ឃ្លាតពាក្យប្រពៃ* *នោះប្រធាននៃ សេចក្ដីវិនាស ។*

6- *បុរសអ្នកមាន ទ្រព្យធនធានច្រើន* *មាសប្រាក់ចំរើន និងគ្រឿងអាហារ*
*លបលាក់របស់ ដែលឆ្ងាញ់ពិសា* *ស៊ីម្នាក់ឯងជា ប្រធានវិនាស ។*

7- *អ្នកដែលប្រកាន់ ជាតិទ្រព្យត្រកូល* *ហើយមិនប្រមូលសាច់ញាតិសន្តាន*
*មើលងាយញាតិខ្លួន ដោយអាងខ្លួនមាន* *នោះជាប្រធានសេចក្ដីវិនាស ។*

8- *ជនអ្នកប្រព្រឹត្តល្បែង៣ប្រការ* *ល្បែងស្រីល្បែងស្រា ល្បែងភ្នាល់ទាំងឡាយ*
*ធ្វើទ្រព្យខ្លួនមានឲ្យអន្តរាយ* *ការល្បែងទាំងឡាយ នោះនាំឲ្យវិនាស ។*

9- *ប្រុសមិនត្រេកអរ នឹងប្រពន្ធខ្លួន* *ហើយទៅជាប់ដួន នឹងស្រីពេស្យា*

ទ្រុស្តនឹងប្រពន្ធ កូនជននានា    ហេតុនោះទៅជា នាំឲ្យវិនាស ។
10- បុរសមានវ័យដែលចាស់ហួសពេក    ហើយមានតម្រេកដោយក្តីតណ្ហា
នាំយកស្រីក្មេង មកធ្វើភរិយា    ហេតុនោះទៅជានាំឲ្យវិនាស ។
11- បុរសតាំងស្រី អ្នកលេងខ្ជះខ្ជាយ    ឬស្រីទាំងឡាយតាំងបុរសនោះ
ដែលជាអ្នកលេង ខ្ជះខ្ជាយដូច្នោះ    អំពើទាំងនោះ នាំឲ្យវិនាស ។
12- ជនណាកើតក្នុងត្រកូលជាក្សត្រ    អ្នកខ្សត់សម្បត្តិ ហើយប្រាថ្នាធំ
ចង់បានជាស្តេច សោយរាជ្យស្តុកស្តម្ភ    ហេតុនោះនឹងនាំឲ្យដល់វិនាស ។

ជនជាបណ្ឌិត គំនិតប្រសើរ    បានឃើញដំណើរនៃហេតុវិនាស
ដល់សត្វក្នុងលោកសន្និវាស    គេចពីវិនាស គប់រកចម្រើន ។

& &
&